ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តកំពត

# សេចក្តីជូនដំណឹង

## ស្តីពី

## ការប្រារព្ធពិធីបុណ្យអុំទូកនៅមាត់ព្រែកកំពង់បាយ ក្រុងកំពត ខេត្តកំពត

**រដ្ឋបាលខេត្ត** មានកិត្តិយសសូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី ថ្នាក់ដឹកនាំមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ និងសាធារណៈជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋ ទាំងអស់មេត្តាជ្រាបថា៖ ដើម្បីត្រៀមចូលរួមអបអរសាទរ **ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក** ឆ្នាំ២០១៨ នាពេលខាងមុខនេះ ដើម្បីរំលឹកដល់គុណូបការៈដ៏អង់អាចក្លាហានរបស់កងទ័ពជើងទឹកខ្មែរ ដែលបានរំដោះទឹកដីរួចផុតពីការជិះជាន់ របស់សត្រូវ ព្រមទាំងដើម្បីឧទ្ទិសកុសលដល់ព្រះគង្គា និងព្រះធរណីដែលបានផ្តល់នូវសេចក្តីសុខសប្បាយ ភោគផលក្នុងការងារកសិកម្ម របរចិញ្ចឹមជីវិតប្រចាំថ្ងៃ ។ **រដ្ឋបាលខេត្ត** បានសម្រេចប្រារព្ធ **ពិធីប្រណាំងទូក** នៅមាត់ព្រែកកំពង់បាយ ក្រុងកំពត ខេត្តកំពត នាថ្ងៃសុក្រ ៩កើត ខែកត្តិក ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ នាពេលខាងមុខ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រីប្រធានមន្ទីរ-អង្គភាពជុំវិញខេត្ត ប្រធានក្រុមហ៊ុន រោងចក្រ សហគ្រាស ពាណិជ្ជករ អាជីវករ សប្បុរសជន និងប្រជាពលរដ្ឋទាំងអស់ មេត្តាជ្រាបជាព័ត៌មាន ព្រមទាំងអញ្ជើញចូលរួមទស្សនា អបអរឲ្យបានច្រើនកុះករ តាមកាលបរិច្ឆេទខាងលើ ដើម្បីញ៉ាំងឲ្យកម្មវិធីនេះប្រព្រឹត្តទៅជោគជ័យ និងប្រកបដោយបរិយាកាសសប្បាយរីករាយ ។៚

ថ្ងៃព្រហ ១៤រោច ខែអស្សុជ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២

កំពត,ថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ២០១៨